ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

# ផែនការគ្រប់គ្រងកន្លែងនេសាទសហគមន៍
# អន្លង់វាលព្រលូងលួងចិត្ត
# សម្រាប់រយៈពេល ៣ ឆ្នាំ
# (កក្កដា ២០១៩ - មិថុនា ២០២២)

| | | |
|---|---|---|
| សហគមន៍នេសាទ | ៖ | អន្លង់វាលព្រលូងលួងចិត្ត |
| ភូមិ | ៖ | អំពិលទឹក |
| ឃុំ | ៖ | កំពង់ចាម |
| ស្រុក | ៖ | សំបូរ |
| ខេត្ត | ៖ | ក្រចេះ |

ខែមករា ឆ្នាំ២០១៩

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

# ផែនការគ្រប់គ្រងកន្លែងនេសាទសហគមន៍
# អន្លង់វាលព្រលូងលួងចិត្ត
# សម្រាប់រយៈពេល ៣ ឆ្នាំ
# ( កក្កដា ២០១៩ - មិថុនា ២០២២ )

| | | |
|---|---|---|
| សហគមន៍នេសាទ | ៖ | អន្លង់វាលព្រលូងលួងចិត្ត |
| ភូមិ | ៖ | អំពិលទឹក |
| ឃុំ | ៖ | កំពង់ចាម |
| ស្រុក | ៖ | សំបូរ |
| ខេត្ត | ៖ | ក្រចេះ |

ខែមករា ឆ្នាំ២០១៩

# មាតិកា


១. ស្ថានភាពទូទៅ ........................................ ១
២. អំពីប្រជាសាស្ត្រ និងសេដ្ឋកិច្ចសង្គម ........................................ ២
ក. ប្រជាពលរដ្ឋ ........................................ ២
ខ. មុខរបរ ........................................ ២
៣. កន្លែងនេសាទ និងធនធានជលផលដែលមាននៅក្នុងកន្លែងនេសាទ ........................................ ៣
ក. ទីតាំង ........................................ ៣
ខ. ដែននេសាទ ........................................ ៣
គ. តំបន់ដែលមានលទ្ធភាពអាចបង្កើតកន្លែងអភិរក្ស ........................................ ៣
ឃ. ធនធានជលផល ........................................ ៤
៤. ការធ្វើនេសាទ ........................................ ៤
ក. អ្នកនេសាទ ........................................ ៤
ខ. ឧបករណ៍នេសាទ ........................................ ៤
គ. ការប៉ាន់ប្រមាណផលនេសាទចាប់បានប្រចាំឆ្នាំ ........................................ ៥
៥. ផែនការគ្រប់គ្រងកន្លែងនេសាទសហគមន៍ ........................................ ៥
ក. ទស្សនៈវិស័យ ........................................ ៥
ខ. គោលបំណងរួម ........................................ ៥
គ. គោលបំណងជាក់លាក់ ........................................ ៥
ឃ. ផែនការសកម្មភាពគ្រប់គ្រងកន្លែងនេសាទសហគមន៍ ........................................ ៦
ឃ.១. ធនធានជលផល និងអេកូឡូស៊ី ........................................ ៦
ឃ.២. ការគាំទ្រជីវភាពប្រជាពលរដ្ឋ ........................................ ៨
ឃ.៣. ការគ្រប់គ្រង ........................................ ១០
ង. ការតាមដាន ត្រួតពិនិត្យ និងវាយតម្លៃ ........................................ ១៣
ច. យុទ្ធសាស្ត្រ ........................................ ១៣
តារាងសង្ខេបផែនការគ្រប់គ្រងកន្លែងនេសាទសហគមន៍ភូមិខ្សាច់លាវរយៈពេល ៣ ឆ្នាំ (២០១៩-២០២២) ........ ១៥
តារាងកម្មវិធីការងារប្រចាំឆ្នាំ (កក្កដា ២០១៩ - មិថុនា ២០២២) ........................................ ២០

# ផែនការគ្រប់គ្រង
# កន្លែងនេសាទសហគមន៍

## ១. ស្ថានភាពទូទៅ

សហគមន៍នេសាទអន្លង់វាលព្រលួងលួងចិត្ត បានបង្កើតឡើងដោយមហាសន្និបាតកំណើតដំបូងនៅឆ្នាំ១៩៩៨ ដោយមានការគាំទ្របច្ចេកទេសនិងថវិកាពីខណ្ឌរដ្ឋបាលជលផលក្រចេះ និងអង្គការអុកស្វាមអូស្ត្រាលី (CAA/Oxfam Australia)។ បន្ទាប់មកក្រោមការគាំទ្របច្ចេកទេសនិងថវិកាពីខណ្ឌរដ្ឋបាលជលផលក្រចេះ និងអង្គការមូលនិធិសកលសម្រាប់ការអភិរក្សធនធានធម្មជាតិ (WWF) សហគមន៍បានបោះឆ្នោតជ្រើសរើសគណៈកម្មការសហគមន៍នេសាទឡើងវិញនៅថ្ងៃទី២ ខែមីនា ឆ្នាំ២០១១ និងបានចុះកិច្ចព្រមព្រៀងកន្លែងនេសាទសហគមន៍រវាងខណ្ឌរដ្ឋបាលជលផលនិងគណៈកម្មការសហគមន៍ នៅថ្ងៃទី៣១ ខែកក្កដា ឆ្នាំ២០១២ និងបានបន្តចុះកិច្ចព្រមព្រៀងកន្លែងនេសាទសហគមន៍អាណត្តិទី២ នៅថ្ងៃទី២៧ កញ្ញា ឆ្នាំ២០១៦។ ដោយមានការគាំទ្របច្ចេកទេស និងថវិកាពីខណ្ឌរដ្ឋបាលជលផលក្រោមគម្រោងគ្រប់គ្រងធនធានទឹកចម្រុះទន្លេមេគង្គ (ដំណាក់កាលទី៣) សហគមន៍បានធ្វើបច្ចុប្បន្នភាពបញ្ជីឈ្មោះសមាជិកសហគមន៍នេសាទឡើងវិញ តាមរយៈកិច្ចប្រជុំនៅថ្ងៃទី១៦ ខែសីហា ឆ្នាំ២០១៨ ដោយសមាជិកដែលបានចុះក្នុងបញ្ជីជាផ្លូវការសរុបចំនួន១៤៥ នាក់ ស្រីមានចំនួន៨១នាក់។ បន្ទាប់មក បានបោះឆ្នោតជ្រើសរើសគណៈកម្មការសហគមន៍ម្តងទៀតនៅថ្ងៃទី១៩ ខែតុលា ឆ្នាំ២០១៨ ដែលគណៈកម្មការដែលទើបជាប់ឆ្នោតថ្មីមានចំនួន០៩នាក់ ស្រី ០១ នាក់ និងបានរៀបចំរចនាសម្ព័ន្ធគ្រប់គ្រង និងបែងចែកតួនាទី ភារកិច្ចទទួលខុសត្រូវតាមការស្ម័គ្រចិត្ត និងការឯកភាពគ្នាក្នុងចំណោមសមាជិកគណៈកម្មការទាំងអស់ និងបានរៀបចំធ្វើបច្ចុបន្នភាពផែនការគ្រប់គ្រងកន្លែងនេសាទសហគមន៍តាមរយៈកិច្ចប្រជុំថ្ងៃទី១២-១៣ ខែកុម្ភៈ ឆ្នាំ២០១៩ និងមហាសន្និបាតអនុម័តផែនការគ្រប់គ្រងកន្លែងនេសាទសហគមន៍ថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៩។

ទន្ទឹមនឹងសមិទ្ធផលដែលសម្រេចបានដូចខាងលើ សហគមន៍នេសាទនៅមានការជួបប្រទះនូវបញ្ហាប្រឈមនានាពាក់ព័ន្ធនឹងធនធានជលផលនិងអេកូឡូស៊ី ជីវភាពប្រជាពលរដ្ឋ និងការគ្រប់គ្រងៈ

-បញ្ហាប្រឈមពាក់ព័ន្ធនឹងធនធានជលផលនិងអេកូឡូស៊ី រួមមានបរិមាណត្រីថយចុះ អន្លង់អភិរក្សកាន់តែរាក់ កំពស់ទឹកឡើងស្រកខុសប្រក្រតី មានស្លែច្រើនពិបាកនេសាទត្រី ទឹកកើតស្លែច្រើន បាក់ដីច្រាំងទន្លេតាមកោះ និងបាត់បង់ព្រៃលិចទឹក ដោយសារការកាប់ទន្ទ្រានយកដី

-បញ្ហាប្រឈមពាក់ព័ន្ធនឹងជីវភាពប្រជាពលរដ្ឋ រួមមានចំនួនប្រជាពលរដ្ឋក្នុងឃុំកើនឡើង ប្រជាពលរដ្ឋគ្មានមុខរបរនិងការងារធ្វើ មានការចំណាកស្រុកដើម្បីរកការងារធ្វើ កសិផលរបស់សហគមន៍លក់មិនដាច់ ដីមិនជាប់ទឹកមិនអាចចិញ្ចឹមត្រីបាន ខ្វះបច្ចេកទេសដាំដំណាំនិងចិញ្ចឹមសត្វ និងខ្វះទុនប្រកបមុខរបរ

-បញ្ហាប្រឈមពាក់ព័ន្ធនឹងការគ្រប់គ្រង រួមមានបទល្មើសនេសាទនៅតែកើតមាន(ដូចជាឆក់ត្រី ដាក់មងក្រឡាធំ វាយមងជាក្រុម វាយសន្ទូចប្រើនុយអប់នេសាទត្រីនៅរដូវត្រីពង) សមាជិកសហគមន៍នេសាទក៏នៅពុំទាន់មានការយល់ដឹងនិងចូលរួមការងារសហគមន៍ឱ្យបានសស្រាក់សស្រាំ នៅមានបទល្មើសនេសាទដោយអ្នកមកពីខាងក្រៅសហគមន៍នេសាទលួចធ្វើនេសាទនៅកន្លែងអភិរក្សជាពិសេសនៅពេលយប់ សហគមន៍នេសាទចុះល្បាតមិនទៀងទាត់ ដោយសារ

ខ្វះទូក ប្រេង និងឧបករណ៍សម្ភារសម្រាប់ល្បាត មិនទាន់មានទីស្នាក់ការសហគមន៍នេសាទសម្រាប់ប្រតិបត្តិការ គណៈកម្មការសហគមន៍នេសាទពុំទាន់មានសមត្ថភាពគ្រប់គ្រាន់ក្នុងការដឹកនាំ សហគមន៍នេសាទនៅតែគិតថាការងារគណៈកម្មការជាការងារបច្ចេកទេស និងជាតួនាទីរបស់បុរស ចំណែកស្ត្រីមានតួនាទីជាអ្នកថែទាំគ្រួសារ ការងារផ្ទះ និងលក់ដូរ ហើយការចូលរួមរបស់ស្ត្រីក្នុងកិច្ចប្រជុំនានាមានចំនួនច្រើន តែការសម្រេចចិត្តនៅមានកម្រិត។

## ២. អំពីប្រជាសាស្ត្រ និងសេដ្ឋកិច្ចសង្គម

### ក. ប្រជាពលរដ្ឋ

ចំនួនប្រជាពលរដ្ឋសរុបនៅក្នុងសហគមន៍មានចំនួន១.៥០៨នាក់ ប្រុសចំនួន៧៥៩នាក់ ស្រី៧៤៩នាក់។ ប្រជាពលរដ្ឋក្នុងសហគមន៍នេសាទជាអ្នកកាន់សាសនាព្រះពុទ្ធ ១០០ %។

ស្ថានភាពប្រជាពលរដ្ឋក្នុងតំបន់សហគមន៍មានដូចខាងក្រោមៈ

- ចំនួនស្ត្រីមេម៉ាយមាន ២៦ នាក់
- ចំនួនជនពិការមាន ១៥ នាក់ ស្រី ៧ នាក់
- ចំនួនចាស់ជរាមាន ១ នាក់ ស្រី គ្មាន
- ចំនួនកុមារកំព្រាក្នុងមាន ៣ នាក់ ស្រី ២ នាក់
- ចំនួនអ្នកមានជំងឺរ៉ាំរ៉ៃក្នុងមាន ៣ នាក់ ស្រី គ្មាន
- កម្រិតសិក្សាអប់រំរួមមានអ្នកមិនចេះអក្សរមានចំនួន ២៨២នាក់ ស្រី១០៩នាក់ ថ្នាក់បឋមសិក្សាចំនួន ២៣២ នាក់ ស្រី ១១២ នាក់ និងកម្រិតមធ្យមសិក្សាចំនួន២១ នាក់ ស្រី១៤ នាក់។

### ខ. មុខរបរ

មុខរបរសំខាន់ៗរបស់ប្រជាពលរដ្ឋក្នុងសហគមន៍នេះរួមមាន ៖

- ធ្វើនេសាទជាលក្ខណៈគ្រួសារចំនួន ១៤០ គ្រួសារ (៣០%)
- ធ្វើស្រែវស្សាចំនួន ១៦៣ គ្រួសារ ទំហំ ១១៤,១០ ហិកតា (៧០%)
- ចិញ្ចឹមសត្វជាលក្ខណគ្រួសារ ១០០ភាគរយនៃគ្រួសារក្នុងភូមិ
- ដាំបន្លែចំនួន ០៥ គ្រួសារ
- ធ្វើចំការរយពេលវែង ចំនួនមនុស្ស ៥០ នាក់ ស្រី ២៨នាក់
- ធ្វើចំការរយពេលខ្លី ចំនួនមនុស្ស ៩២ នាក់ ស្រី ៥០នាក់
- ធ្វើជាងផ្ទះចំនួន ០២ គ្រួសារ
- ធ្វើជាងកាត់ដេរ ០២ គ្រួសារ
- មន្ត្រីរាជការ ០៦នាក់ ស្ត្រីចំនួន ០១នាក់
- ចំណាកស្រុកទៅប្រទេសថៃ ចំនួន ០១នាក់
- លក់ដូរចាប់ហួយចំនួន ០៦ គ្រួសារ។

## ៣. កន្លែងនេសាទ និងធនធានជលផលដែលមាននៅក្នុងកន្លែងនេសាទ

ក. ទីតាំង

កន្លែងនេសាទសហគមន៍អន្លង់វាលព្រលូងលួងចិត្តជាទ្រព្យសម្បត្តិសាធារណៈរបស់រដ្ឋ។ កន្លែងនេសាទសហគមន៍អន្លង់វាលព្រលូងលួងចិត្តស្ថិតនៅតាមដងទន្លេមេគង្គ មានទំហំ ៥៧១,៨៧ ហិកតា និងមាននិយាមការដូចមានចែងនៅក្នុងកិច្ចព្រមព្រៀង។

មានព្រំប្រទល់ ៖

- ខាងជើងទល់នឹងកន្លែងនេសាទសហគមន៍អូរក្រសាំង
- ខាងត្បូងទល់នឹងភូមិកំពង់ក្របី ឃុំកំពង់ចាម ស្រុកសំបូរ ខេត្តក្រចេះ
- ខាងកើតទល់នឹងកោះរងាវ ក្នុងភូមិអំពិលទឹក ឃុំកំពង់ចាម ស្រុកសំបូរ ខេត្តក្រចេះ
- ខាងលិចទល់នឹងកន្លែងនេសាទសហគមន៍ក្រហមគោបាក់។

ខ. ដែននេសាទ

កន្លែងនេសាទសហគមន៍អន្លង់វាលព្រលូងលួងចិត្តស្ថិតនៅតាមដងទន្លេមេគង្គ មានកោះ និង ព្រៃលិចទឹកដុះរាយនៅតាមមាត់ច្រាំងទន្លេ។ កន្លែងនេសាទសហគមន៍អន្លង់វាលព្រលូងលួងចិត្ត មានអន្លង់ចំនួន ៣ និង អូរចំនួន ៩ ៖

| | | |
|---|---|---|
| - អន្លង់ខ្សាច់ស្វាយ | ទំហំ ៨,៩៦ ហិកតា | មានទឹកពេញមួយឆ្នាំ |
| - អន្លង់តាម៉ាវ | ទំហំ ៨,៨៥ ហិកតា | មានទឹកពេញមួយឆ្នាំ |
| - អន្លង់វាលព្រលូង | ទំហំ ៣១,៧២ ហិកតា | មានទឹកពេញមួយឆ្នាំ |
| - អូរប្រលៃ | ប្រវែង ៣០០ ម៉ែត្រ | មានទឹកពីកក្កដាដល់មេសា |
| - អូរតាម៉ៅ | ប្រវែង ២០០ ម៉ែត្រ | មានទឹកពីកក្កដាដល់តុលា |
| - អូរវិន | ប្រវែង ១០០ ម៉ែត្រ | មានទឹកពីកក្កដាដល់តុលា |
| - អូរតាភន | ប្រវែង ១៥០ ម៉ែត្រ | មានទឹកពីកក្កដាដល់តុលា |
| - អូរសាន | ប្រវែង ២០០ ម៉ែត្រ | មានទឹកពីកក្កដាដល់តុលា |
| - អូរវាលព្រលូង | ប្រវែង ១០០ ម៉ែត្រ | មានទឹកពីកក្កដាដល់តុលា |
| - អូរឃើន | ប្រវែង ២៥០ ម៉ែត្រ | មានទឹកពីកក្កដាដល់តុលា |
| - អូរតាយ៉ាវ | ប្រវែង ៤០០ ម៉ែត្រ | មានទឹកពីកក្កដាដល់តុលា |
| - អូរឃាត | ប្រវែង ២០០ ម៉ែត្រ | មានទឹកពីកក្កដាដល់តុលា |

គ. តំបន់ដែលមានលទ្ធភាពអាចបង្កើតកន្លែងអភិរក្ស

សមាជិកសហគមន៍នេសាទបានឯកភាពគ្នាកំណត់យកអន្លង់ខ្សាច់ស្វាយ ទំហំ ៨,៩៦ ហិកតា អន្លង់តាម៉ាវ ទំហំ ៨,៨៥ ហិកតា និង អន្លង់វាលព្រលូង ទំហំ ៣១,៧២ ហិកតា ជាតំបន់ដែលមានសក្តានុពលសម្រាប់អភិរក្សត្រីមេពូជតាមការសម្រេចរបស់មហាសន្និបាត។

ឃ. ធនធានជលផល

ឃ.១. ប្រភេទត្រី ៖

ត្រីខ្យា ត្រីឆ្លាំង ត្រីទ្រនេល ត្រីឆ្តោក ត្រីក្រសក់ ត្រីក្អែក ត្រីក្តី ត្រីក្រាយ ត្រីឆ្តោរ ត្រីរ៉ស់ ត្រីអំបូង ត្រីសណ្តាយ ត្រីក្លាំងហាយ ត្រីប្រា ត្រីកែស ត្រីប្រាកណ្តុរ ត្រីពោធិ៍ ត្រីព្រលូង ត្រីប៉ាវ៉ា ត្រីដំរី ត្រីប៉ាស៊ីអី ត្រីផ្ទក់ ត្រីឆ្លញ ត្រីខ្ទឹង ត្រីរៀល ត្រីក្រឡង់ ត្រីកញ្ចុះ ត្រីគ្រំ ត្រីក្រាញ់ ត្រីកន្ធប់ ត្រីចេក ត្រីសារិកាកែវ ត្រីឆ្ពិន ត្រីកាហែ ត្រីច្រកែង ត្រីចង្វារ ត្រីអណ្តែង ត្រីស្លឹកឫស្សី ត្រីកំភ្លាវ ត្រីតាអោន ត្រីគល់រាំង ត្រីបបែល ត្រីលលកស ត្រីស្នក់ ត្រីខ្មាន់ ត្រីកាទឹម ត្រីក្រុស ត្រីកញ្ជ្រូក ត្រីអាចម៌កុក ត្រីកំបុតច្រមុះ ត្រីកញ្ជនជ័យ ត្រីក្របី ត្រីកែ ត្រីឈ្មៀត ត្រីកំពត ត្រីថ្មោង ត្រីអន្ទង់ ត្រីខ្លា ត្រីប្រម៉ា ត្រីរាហ៊ូ ត្រីអណ្តាតឆ្កែ ត្រីស្លាត ត្រីនាងល្វើង ត្រីកន្រ្ទងប្រេង ត្រីរមាស ត្រីតាយ៉ូ។

ឃ.២. ប្រភេទវារីសត្វ ៖

អណ្តើក កន្ធាយ ល្មិច និង សត្វផ្សោត។

ឃ.៣. ព្រៃលិចទឹក និងវារីរុក្ខជាតិ

ដើមរំ ដើមអណ្តែង ដើមអញ្ចែង ដើមអញ្ចេ ដើមទន្លា ដើមត្រស់ ដើមរាំង ដើមក្តុល ដើមថ្កៅ ដើមគ្រៃង ដើមស្លូត និងដើមបបុស។

## ៤. ការធ្វើនេសាទ

ក. អ្នកនេសាទ

- អ្នកនេសាទជាសមាជិកសហគមន៍នេសាទមានចំនួន ១៤៥ នាក់ ស្រី ៨១ នាក់
- អ្នកនេសាទមិនមែនជាសមាជិកសហគមន៍នេសាទក្នុងសហគមន៍មានចំនួន ៤១៧ នាក់ ស្រី១២៥
- ប៉ាន់ស្មានអ្នកនេសាទមិនមែនជាសមាជិកដែលមកពីក្រៅសហគមន៍ចំនួន ៣៩ នាក់ ស្រី ១៥ នាក់។

ខ. ឧបករណ៍នេសាទ

| ប្រភេទឧបករណ៍ | ឯកតា | ចំនួន | | | ទំហំ ប្រវែង | | | រដូវប្រើប្រាស់ឧបករណ៍នេសាទ |
|---|---|---|---|---|---|---|---|---|
| | | សមាជិក | មិនមែនសមាជិក | អ្នកខាងក្រៅភូមិ | សមាជិក | មិនមែនសមាជិក | អ្នកខាងក្រៅភូមិ | |
| សំណាញ់ | វង់ | ៤៥ | ១៥០ | ២០ | ប្រវែង ៥ម ក្រឡា ២,៥ ម | ប្រវែង ៥ម ក្រឡា២,៥ ម | ប្រវែង ៥ម ក្រឡា ២,៥ សម | មករា - ធ្នូ |
| បង្កៃ | ផ្លែ | ៧៥ | ១៥០ | ២០០ | ផ្លែលេខ៧-១២ | ផ្លែលេខ៧-១២ | ផ្លែលេខ៧-១២ | មិថុនា - ធ្នូ |
| សន្ទូចរនង | សាង ១០០ផ្លែ | ៤០ | ៣៥០ | ២០ | ផ្លែលេខ១២-១៣ | ផ្លែលេខ | ផ្លែលេខ | មករា - ធ្នូ |
| លប | គ្រឿង | ១៥០ | ១.៥០០ | ២០ | មុខ១មx១,៨ម | មុខ១មx១,៨ម | មុខ១មx១,៨ម | មិថុនា - ធ្នូ |
| ចាន់ | គ្រឿង | ៣០ | | | មុខ ០,៥ ម កម្ពស់ ១,៣ ម | | | មិថុនា - ធ្នូ |

ម=ម៉ែត្រ ស.ម=សង្ទីម៉ែត្រ

ប្រភេទទូកកាណូត

| ប្រភេទទូកកាណូត | ចំនួន (ទូក) | | | ចំណុះ (គីឡូក្រាម) | | | កម្លាំងសេះ | | |
|---|---|---|---|---|---|---|---|---|---|
| | សមាជិក | មិនមែនសមាជិក | អ្នកខាងក្រៅភូមិ | សមាជិក | មិនមែនសមាជិក | អ្នកខាងក្រៅភូមិ | សមាជិក | មិនមែនសមាជិក | អ្នកខាងក្រៅភូមិ |
| ទូកចែវ/អុំ | ១៧ | ១០០ | | ២០០-៣០០ | | | | | |
| ទូកមានម៉ាស៊ីន | ១០០ | ២៥០ | ៣៩ | ២០០-៣០០ | ២០០-៣០០ | ២០០-៣០០ | ៦-១៨សេះ | ៦-១៨ សេះ | ៦-១៨ សេះ |

គ. ការប៉ាន់ប្រមាណផលនេសាទចាប់បានប្រចាំឆ្នាំ

| ប្រភេទផលនេសាទ | បរិមាណផលនេសាទចាប់បានគិតជាមធ្យមក្នុង១គ្រួសារ (គីឡូក្រាម) | | |
|---|---|---|---|
| | រដូវប្រាំង | រដូវវស្សា | សរុបប្រចាំឆ្នាំ |
| ត្រី | ៣៧៩,៣០ | ៥៨៦,៨៦ | ៩១៦,១៦ |

## ៥. ផែនការគ្រប់គ្រងតំបន់នេសាទសហគមន៍

### ក.ទស្សនៈវិស័យ

សហគមន៍នេសាទ អន្លង់វាលព្រលូងលូងចិត្ត មានទស្សនវិស័យរួមចំណែកគ្រប់គ្រងធនធានជលផលប្រកបដោយសមធម៌ និងចីរភាព ដើម្បីរួមចំណែកកាត់បន្ថយភាពក្រីក្ររបស់ប្រជាពលរដ្ឋ ។

### ខ. គោលបំណងរួម

ដើម្បីសម្រេចបាននូវទស្សនវិស័យខាងលើ សហគមន៍នេសាទ មានគោលបំណងរួមដូចខាងក្រោមៈ

- ធ្វើឱ្យត្រីមានការកើនឡើង
- បង្កើនប្រាក់ចំណូលដល់សមាជិកសហគមន៍នេសាទ
- បទល្មើសនេសាទមានការថយចុះ។

### គ. គោលបំណងជាក់លាក់

- ការពារ និងដាំព្រៃលិចទឹកជាជម្រកត្រីនៅតាមច្រាំងទន្លេ
- បង្កើនជម្រើសមុខរបរចិញ្ចឹមជីវិតដល់សមាជិកសហគមន៍នេសាទ តាមរយៈការចិញ្ចឹមសត្វ ត្រី ដាំបន្លែ និងមានទីផ្សារសម្រាប់កសិផល ។
- កាត់បន្ថយបទល្មើសនេសាទ តាមរយៈការផ្សព្វផ្សាយ និងចុះល្បាត ដោយមានកិច្ចសហការជាមួយអាជ្ញាធរដែនដី និងអ្នកពាក់ព័ន្ធ

ឃ. ផែនការសកម្មភាពគ្រប់គ្រងកន្លែងនេសាទសហគមន៍

ឃ.១. ធនធានជលផល និងអេកូឡូស៊ី

ឃ.១.១. ផែនការប្រើប្រាស់ឧបករណ៍នេសាទ

ផែនការប្រើប្រាស់ឧបករណ៍នេសាទនៅក្នុងកន្លែងនេសាទសហគមន៍ គឺគិតគូរអំពីប្រភេទដែននេសាទ ប្រភេទ ទំហំ ប្រវែងចំនួនឧបករណ៍នេសាទ ចំនួនអ្នកនេសាទ និងរដូវនេសាទ ត្រូវបានរៀបចំខាងក្រោម ៖

| ឈ្មោះ/ទីតាំងកន្លែងនេសាទ | ពេលវេលាធ្វើនេសាទ | ឧបករណ៍នេសាទអនុញ្ញាតឱ្យប្រើ | | | ការប៉ាន់ស្មានថវិកា (ដុល្លារ) |
|---|---|---|---|---|---|
| | | ប្រភេទ | ទំហំ / ប្រវែង | ចំនួន | |
| នៅតាមដងទន្លេមេគង្គ នៅខាងក្រៅអន្លង់អភិរក្សសហគមន៍ | មករា - ធ្នូ | សំណាញ់ | ប្រវែង៦ម<br>ក្រឡា២ - ១៥ ស.ម | ៤៥ វង់ | ១៥០<br>(៥០/ឆ្នាំ សម្រាប់ការងារផ្សព្វផ្សាយ) |
| | មករា - ធ្នូ | សន្ទូចរនង | ផ្លែលេខ ៩-១២ | ៤០ សាង | |
| | មិថុនា - ធ្នូ | លប | មុខ១ម បណ្តោយ ២ម | ១៥០ លប | |
| | មិថុនា - ធ្នូ | ចាន់ | មុខ០,៥ម កម្ពស់១,៣ម | ៣០ ចាន់ | |
| | មិថុនា - ធ្នូ | ប៉ោង | មុខ០,៥ ម កម្ពស់១,៣ម | ១០ គ្រឿង | |
| | មិថុនា - ធ្នូ | បង្កៃ | | ៧៥ ផ្លែ | |
| | មិថុនា - ធ្នូ | ឈ្នាងក្រាំ | | ១០ គ្រឿង | |

ឃ.១.២. ផែនការកំណត់ និងរៀបចំកន្លែងអភិរក្សសហគមន៍

ផែនការកំណត់ និងរៀបចំកន្លែងអភិរក្សសហគមន៍ត្រូវបានរៀបចំខាងក្រោម ៖

| ឈ្មោះ / ទីតាំង | ទំហំ (ហិចតា) | ប្រភេទនៃការអភិរក្ស | សកម្មភាព | ការប៉ាន់ស្មានថវិកា (ដុល្លារ) | ថ្ងៃខែឆ្នាំចាប់ផ្តើម | ថ្ងៃខែឆ្នាំបញ្ចប់ |
|---|---|---|---|---|---|---|
| អន្លង់ខ្សាច់ស្វាយ | ៨,៩៦ | • ត្រីគ្រប់ប្រភេទ<br>• សត្វទឹកគ្រប់ប្រភេទ<br>• ព្រៃលិចទឹកគ្រប់ប្រភេទ | • ដាក់ពោង និងស្លាកសញ្ញាតាមអន្លង់១២ (១២x២០០) | ២.៤០០ | កក្កដា ២០១៩ | មិថុនា ២០២២ |
| អន្លង់តាម៉ាវ | ៨,៨៥ | | • តម្លើងផ្ទាំងផ្សព្វផ្សាយ២អំពីច្បាប់ជលផល និងការអភិរក្ស (២x២០០) | ៤០០ | | |
| អន្លង់វាលព្រលូង | ៣១,៧២ | | • លែងកូនត្រីពូជ៣លើក(៣លើក x៥០០) | ១.៥០០ | | |

### ឃ.១.៣. ផែនការបោះបង្គោលព្រំប្រទល់ និងផ្ទាំងប៉ាណូផែនទីកន្លែងនេសាទសហគមន៍

ផែនការបោះបង្គោលព្រំប្រទល់ និងផ្ទាំងប៉ាណូផែនទីកន្លែងនេសាទសហគមន៍ត្រូវបានរៀបចំខាងក្រោម ៖

| ឈ្មោះ / ទីតាំង | សកម្មភាព | ចំនួន | ការប៉ាន់ស្មានថវិកា(ដុល្លារ) | ថ្ងៃ ខែ ឆ្នាំ ចាប់ផ្តើម | ថ្ងៃ ខែ ឆ្នាំ បញ្ចប់ |
|---|---|---|---|---|---|
| ក្បែរចំការតាសែត | រៀបចំ និងលើកផ្ទាំងប៉ាណូផែនទីកន្លែងនេសាទសហគមន៍(ឱ្យស្ត្រី និងបុរសជាគណៈកម្មាការសហគមន៍នេសាទចូលរួមសម្រេចចិត្តក្នុងការកំណត់ទីតាំង) | ១ ផ្ទាំង (១x៣០០) | ៣០០ | តុលា ២០១៩ | ធ្នូ ២០១៩ |

### ឃ.១.៤. ផែនការគ្រប់គ្រងព្រៃលិចទឹក

ផែនការគ្រប់គ្រងព្រៃលិចទឹក ត្រូវបានរៀបចំខាងក្រោម ៖

| ឈ្មោះទីតាំង | ទំហំ (ហិកតា) | ប្រភេទកូនឈើដែលត្រូវដាំ និងការពារ | សកម្មភាព | ការប៉ាន់ស្មានថវិកា (ដុល្លារ) | ថ្ងៃខែឆ្នាំ ចាប់ផ្តើម | ថ្ងៃខែឆ្នាំ បញ្ចប់ |
|---|---|---|---|---|---|---|
| ដាំតាមច្រាំងទន្លេ និងមាត់អូរ | ១០-៣០ ម៉ែត្រ តាមមាត់អូរ ព្រែក ទន្លេ | ព្រៃលិចទឹកដែលត្រូវការពាររួមមាន ក្រែង រៃ គ្រស់ រាំង ទន្លា | • ប្រជុំផ្សព្វផ្សាយពីផលប្រយោជន៍ព្រៃលិចទឹក (ស្ត្រីជាគណៈកម្មការសហគមន៍នេសាទចូលរួមផ្សព្វផ្សាយពីផលប្រយោជន៍ព្រៃលិចទឹក ការពារព្រៃលិចទឹក និងដាក់ស្លាកសញ្ញាសម្គាល់)<br>• ការពារព្រៃលិចទឹកដែលមានស្រាប់<br>• ដាក់ស្លាកសញ្ញាហាមកាប់ព្រៃលិចទឹក និងស្លាកសញ្ញាសម្គាល់<br>• ដាំព្រៃលិចទឹក<br>• ចុះល្បាតជាប្រចាំ | ៣០០ | កក្កដា ២០១៩ | មិថុនា ២០២២ |

ឃ.២. ការគាំទ្រជីវភាពប្រជាពលរដ្ឋ

ឃ.២.១. ផែនការមុខរបរបង្កើនប្រាក់ចំណូល

ផែនការមុខរបរបង្កើនប្រាក់ចំណូលត្រូវបានរៀបចំខាងក្រោម ៖

| ប្រភេទមុខរបរ | សកម្មភាព | ប្រភេទពូជ | បរិមាណ | ការប៉ាន់ស្មានថវិកា (ដុល្លារ) | ថ្ងៃខែឆ្នាំចាប់ផ្តើម | ថ្ងៃខែឆ្នាំប្រមូលផល |
|---|---|---|---|---|---|---|
| ចិញ្ចឹមមាន់តាមបច្ចេកទេសជាលក្ខណៈគ្រួសារ | • ជ្រើសរើសគ្រួសារ<br>• បណ្តុះបណ្តាលពីបច្ចេកទេសចិញ្ចឹមមាន់ជាលក្ខណៈគ្រួសារ<br>• ផ្តល់ពូជ និងទិញសម្ភារ<br>• តាមដានត្រួតពិនិត្យ | ក្នុងស្រុក | ៣០គ្រួសារ (៣០០ក្បាល x៥) | ១.៥០០ | កក្កដា ២០១៩ | មិថុនា ២០២២ |
| ចិញ្ចឹមទាតាមបច្ចេកទេសជាលក្ខណៈគ្រួសារ | • ជ្រើសរើសគ្រួសារ<br>• បណ្តុះបណ្តាលពីបច្ចេកទេសចិញ្ចឹមទាជាលក្ខណៈគ្រួសារ<br>• ផ្តល់ពូជ និងទិញសម្ភារ<br>• តាមដានត្រួតពិនិត្យ | ក្នុងស្រុក | ២០គ្រួសារ (២០០ក្បាល x៥) | ១.០០០ | កក្កដា ២០១៩ | មិថុនា ២០២២ |
| ចិញ្ចឹមគោតាមបច្ចេកទេសជាលក្ខណៈគ្រួសារ | • ជ្រើសរើសគ្រួសារ<br>• បណ្តុះបណ្តាលពីបច្ចេកទេសចិញ្ចឹមគោជាលក្ខណៈគ្រួសារ<br>• ផ្តល់ពូជ និងទិញសម្ភារ<br>• តាមដានត្រួតពិនិត្យ | ក្នុងស្រុក | ៥០គ្រួសារ (៥០ក្បាលx ៣០០) | ១៥.០០០ | កក្កដា ២០១៩ | មិថុនា ២០២២ |
| ចិញ្ចឹមជ្រូកតាមបច្ចេកទេសជាលក្ខណៈគ្រួសារ | • ជ្រើសរើសគ្រួសារ<br>• បណ្តុះបណ្តាល បច្ចេកទេសចិញ្ចឹមជ្រូកជាលក្ខណៈគ្រួសារ<br>• ផ្តល់ពូជ និងទិញសម្ភារ<br>• តាមដានត្រួតពិនិត្យ | ក្នុងស្រុក | ៥គ្រួសារ (១០ក្បាលx ៥០) | ៥០០ | កក្កដា ២០១៩ | មិថុនា ២០២២ |
| សួនបន្លែតាមលក្ខណៈគ្រួសារ | • ជ្រើសរើសគ្រួសារកសិករស្ម័គ្រចិត្ត<br>• បណ្តុះបណ្តាលបច្ចេកទេសធ្វើសួនបន្លែជាគ្រួសារ<br>• ចែកគ្រាប់ពូជ អនុវត្តផ្ទាល់<br>• តាមដានត្រួតពិនិត្យ | បន្លែ៥មុខ (ស្ពៃ ត្រកួន ននោង សណ្តែកកួរ ត្រប់វែង) | ១៥ គ្រួសារ (១៥គ្រួសារx ៥០) | ៧៥០ | កក្កដា ២០១៩ | មិថុនា ២០២២ |
| បណ្តុះផ្សិត | • ជ្រើសរើសគ្រួសារកសិករស្ម័គ្រចិត្ត<br>• បណ្តុះបណ្តាលបច្ចេកទេសបណ្តុះផ្សិត និងធ្វើមេផ្សិត<br>• អនុវត្តផ្ទាល់ | ផ្សិតចំបើង និង ផ្សិតអំបោះ | ៥ គ្រួសារ (៥គ្រួសារx ៥០) | ២៥០ | កក្កដា ២០១៩ | មិថុនា ២០២២ |

| ប្រភេទមុខរបរ | សកម្មភាព | ប្រភេទពូជ | បរិមាណ | ការប៉ាន់ស្មានថវិកា (ដុល្លារ) | ថ្ងៃខែឆ្នាំចាប់ផ្តើម | ថ្ងៃខែឆ្នាំប្រមូលផល |
|---|---|---|---|---|---|---|
| | • តាមដានត្រួតពិនិត្យ | | | | | |
| ធ្វើមេផ្សិត | • ជ្រើសរើសគ្រួសារកសិករស្ម័គ្រចិត្ត<br>• បណ្តុះបណ្តាលបច្ចេកទេសធ្វើមេផ្សិត<br>• អនុវត្តផ្ទាល់<br>• តាមដានត្រួតពិនិត្យ | ផ្សិតចំបើង ផ្សិតអំបោះ | ១ គ្រួសារ (១គ្រួសារx ៣០០) | ៣០០ | កក្កដា ២០១៩ | មិថុនា ២០២២ |

### ឃ.២.២. ផែនការអភិវឌ្ឍន៍វារីវប្បកម្ម

ផែនការអភិវឌ្ឍន៍វារីវប្បកម្ម ត្រូវបានរៀបចំខាងក្រោម ៖

| ប្រភេទវារីវប្បកម្ម | សកម្មភាព | ចំនួន | បរិមាណ | ការប៉ាន់ស្មានថវិកា(ដុល្លារ) | ថ្ងៃខែឆ្នាំចាប់ផ្តើម | ថ្ងៃខែឆ្នាំប្រមូលផល |
|---|---|---|---|---|---|---|
| ចិញ្ចឹមត្រី អណ្តែងក្នុងអាងតាមបច្ចេកទេសជាលក្ខណៈគ្រួសារ | • ជ្រើសរើសកសិករស្ម័គ្រចិត្ត<br>• បណ្តុះបណ្តាលបច្ចេកទេសចិញ្ចឹមត្រីអណ្តែងជាលក្ខណៈគ្រួសារ<br>• រៀបចំស្រះចិញ្ចឹមត្រី<br>• ផ្តល់កូនត្រី<br>• តាមដានត្រួតពិនិត្យ | ស្រះប្លាស្ទិក ឬ អាងស៊ីម៉ង់ចំនួន ០១/គ្រួសារ (ទំហំ ៤មx៦មx១ម) | ៥គ្រួសារ (៥គ្រួសារx ៥០០) | ២.៥០០ | កក្កដា ២០១៩ | មិថុនា ២០២២ |

### ឃ.២.៣. ផែនការរៀបចំ និងពង្រឹងក្រុមសន្សំប្រាក់

ផែនការរៀបចំ និងពង្រឹងក្រុមសន្សំប្រាក់ ត្រូវបានរៀបចំខាងក្រោម ៖

| ប្រភេទមុខរបរ | សកម្មភាព | ការប៉ាន់ស្មានថវិកា (ដុល្លារ) | ថ្ងៃខែឆ្នាំចាប់ផ្តើម | ថ្ងៃខែឆ្នាំបញ្ចប់ |
|---|---|---|---|---|
| បង្កើតក្រុមសន្សំប្រាក់ចំនួន ៣ ក្រុមបន្ថែម | • ផ្សព្វផ្សាយទស្សនៈក្រុមសន្សំដល់សហគមន៍<br>• ជ្រើសរើសអ្នកទទួលផល<br>• បោះឆ្នោតជ្រើសរើសប្រធានក្រុម<br>• បង្កើតគោលការណ៍ និងបទបញ្ជាផ្ទៃក្នុង<br>• ផ្តល់ទុនដល់ក្រុម<br>• តាមដាន និង ត្រួតពិនិត្យ | ៩០០ (៣ក្រុមx ៣០០) | កក្កដា ២០១៩ | មិថុនា ២០២២ |

ឃ.២.៤. ផែនការសេវាសហគមន៍ និងហេដ្ឋារចនាសម្ព័ន្ធខ្នាតតូច

ផែនការសេវាសហគមន៍ និងហេដ្ឋារចនាសម្ព័ន្ធខ្នាតតូច ត្រូវបានរៀបចំខាងក្រោម ៖

| សកម្មភាព | ចំនួន | ការប៉ាន់ស្មានថវិកា(ដុល្លារ) | ថ្ងៃខែឆ្នាំចាប់ផ្តើម | ថ្ងៃខែឆ្នាំបញ្ចប់ |
|---|---|---|---|---|
| ជួសជុលផ្លូវលំក្នុងភូមិប្រវែង ២.០០០ ម៉ែត្រ | ១ ខ្សែ | ២០.០០០ | កក្កដា ២០១៩ | មិថុនា ២០២២ |
| ជួសជុលស្ពានឈើក្នុងភូមិ | ២ ស្ពាន | ២០.០០០ | កក្កដា ២០១៩ | មិថុនា ២០២២ |
| ដាក់លូកាត់ផ្លូវ | ២ កន្លែង | ៣.០០០ | កក្កដា ២០១៩ | មិថុនា ២០២២ |

ឃ.៣. ការគ្រប់គ្រង

ឃ.៣.១. ផែនការសកម្មភាពចុះល្បាតទប់ស្កាត់បទល្មើស

ផែនការសកម្មភាពចុះល្បាតទប់ស្កាត់បទល្មើស ត្រូវបានរៀបចំខាងក្រោម ៖

| សកម្មភាព | តម្រូវការសម្ភារ | ចំនួន | ការប៉ាន់ស្មានថវិកា (ដុល្លារ) | ថ្ងៃខែឆ្នាំចាប់ផ្តើម | ថ្ងៃខែឆ្នាំបញ្ចប់ |
|---|---|---|---|---|---|
| សហគមន៍ចុះល្បាតដោយខ្លួនឯង | | ៥ដង/១ខែ (៥ដងx១២ខែx៣x២៥) | ៤.៥០០ | កក្កដា ២០១៩ | មិថុនា ២០២២ |
| ចុះល្បាតដោយសហការជាមួយអាជ្ញាធរមូលដ្ឋានដើម្បីទប់ស្កាត់បទល្មើស | | ២ដង/១ខែ (២ដងx១២ខែx៣x២៥) | ១.៨០០ | កក្កដា ២០១៩ | មិថុនា ២០២២ |
| ផ្តល់សម្ភារល្បាត១ឈុត | អាវពោង | ១២ អាវ | ១.០០០ | កក្កដា ២០១៩ | មិថុនា ២០២២ |
| | អាវភ្លៀង | ១២ អាវ | | | |
| | គោមបំភ្លឺពាក់ក្បាល | ២ គោម | | | |
| | វិទ្យុទាក់ទង | ២ គ្រឿង | | | |
| | កែវយឹត | ២ គ្រឿង | | | |
| | ម៉ាស៊ីនថត | ១ គ្រឿង | | | |
| | អង្រឹង | ១២ | | | |
| | តង់គ្របទូក៤មx៦ម | ២ | | | |
| | សម្ភារត្រួតពិនិត្យទឹក | ១គ្រឿង | | | |
| | ស្លាបចក្រ | ៦គ្រឿង | | | |
| | សោរជួសជុលទូក | ១សម្រាប់ | | | |
| | សោរច្រវាក់ចាក់ទូក | ២ ឈុត | | | |
| | អាវយឺត | ២៤ អាវ | | | |
| ទិញទូកស្ទាច់និ ម៉ាស៊ីន | | ២ គ្រឿង | ៣.០០០ | សីហា ២០១៩ | ២០២០ |

| | | | | | |
|---|---|---|---|---|---|
| ប្រេងសម្រាប់ល្បាត | | ១០០លីត្រ/ខែ (១០០លីត្រx៣៦ខែx១) | ៣.៦០០ | កក្កដា ២០១៩ | មិថុនា ២០២២ |
| សេវាជួសជុល ថែទាំទូកនិងម៉ាស៊ីន | | ២ដង/ឆ្នាំ (៦ដងx១០០) | ៦០០ | | |
| សាងសង់ទីស្នាក់ការសហគមន៍នេសាទ(ដីសាលាឆទាន) | | ១ កន្លែង | ៣.០០០ | សីហា ២០១៩ | ២០២០ |

### ឃ.៣.២. ផែនការពង្រឹងគណៈកម្មការសហគមន៍នេសាទ

ផែនការពង្រឹងគណៈកម្មការសហគមន៍នេសាទ ត្រូវបានរៀបចំខាងក្រោមៈ

| សកម្មភាព | ចំនួន | ការប៉ាន់ស្មានថវិកា (ដុល្លារ) | ថ្ងៃខែឆ្នាំចាប់ផ្តើម | ថ្ងៃខែឆ្នាំបញ្ចប់ |
|---|---|---|---|---|
| ប្រជុំប្រចាំខែរបស់គណៈកម្មការសហគមន៍នេសាទ | ១ដង/១ខែ(៣៦ដងx | ៣៦០ | កក្កដា ២០១៩ | មិថុនា ២០២២ |
| ចូលរួមប្រជុំប្រចាំខែជាមួយក្រុមប្រឹក្សាឃុំ | ១០) | ៣៦០ | | |
| បណ្តុះបណ្តាលអំពីរបៀបធ្វើកំណត់ហេតុ សរសេរលិខិតរដ្ឋបាលរបាយការណ៍ និងរៀបចំទុកឯកសារ | ១លើក/១ឆ្នាំ (៣លើកx២០) | ៦០ | | |
| បណ្តុះបណ្តាលអំពីការដោះស្រាយទំនាស់ | | ៦០ | | |
| បណ្តុះបណ្តាលពីភាពជាអ្នកដឹកនាំ និងការងារគ្រប់គ្រង | | ៦០ | | |
| បណ្តុះបណ្តាលអំពីការរៀបចំផែនការសកម្មភាពការងារ | | ៦០ | | |
| បណ្តុះបណ្តាលអំពីការកត់ត្រាចំណាយចំណូល | | ៦០ | | |
| បណ្តុះបណ្តាលអំពីការសរសេរសំណើថវិកា | | ៦០ | | |

### ឃ.៣.៣. ផែនការបង្កើនការយល់ដឹងដល់សមាជិកសហគមន៍នេសាទ

ផែនការបង្កើនការយល់ដឹងដល់សមាជិកសហគមន៍នេសាទ ត្រូវបានរៀបចំខាងក្រោមៈ

| ផែនការ | សកម្មភាព | ចំនួន | ការប៉ាន់ស្មានថវិកា (ដុល្លារ) | ថ្ងៃខែឆ្នាំចាប់ផ្តើម | ថ្ងៃខែឆ្នាំបញ្ចប់ |
|---|---|---|---|---|---|
| បង្កើនការយល់ដឹងដល់សមាជិកសហគមន៍នេសាទ | ផ្សព្វផ្សាយលក្ខន្តិកៈ និងបទបញ្ជាផ្ទៃក្នុងសហគមន៍នេសាទ | ២ដង/ឆ្នាំ (៦ដងx២៥) | ១៥០ | កក្កដា ២០១៩ | មិថុនា ២០២២ |
| | ផ្សព្វផ្សាយកិច្ចព្រមព្រៀងសហគមន៍នេសាទ | ១ដង/ឆ្នាំ (៣ដងx២៥) | ៧៥ | | |
| | ផ្សព្វផ្សាយកន្លែងអភិរក្សស.ន | | ៧៥ | | |
| | ផ្សព្វផ្សាយពីការប្រមូលប្រាក់សមាជិកភាព ភាគទានប្រចាំឆ្នាំ និង | ១ដង/ឆ្នាំ (៣ដងx១០) | ៣០ | | |

| | | | | | |
|---|---|---|---|---|---|
| | ចំណូលចំណាយ | | | | |
| | ផ្សព្វផ្សាយច្បាប់ជលផល និងលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធ | ១ដង/ឆ្នាំ (៣ដងx២៥) | ៧៥ | កក្កដា ២០១៩ | មិថុនា ២០២២ |
| | យុទ្ធនាការផ្សព្វផ្សាយការយល់ដឹងអំពីសារប្រយោជន៍ធនធានជលផល | ១ដង/ឆ្នាំ (៣ដងx១០០) | ៣០០ | កក្កដា ២០១៩ | មិថុនា ២០២២ |
| | ប្រជុំផ្សព្វផ្សាយអំពីតួនាទីរបស់បុរសស្ត្រីក្នុងសហគមន៍នេសាទនិងការងារផ្ទះ សមភាពនិងសមធម៌យេនឌ័រ | ១ដង/ឆ្នាំ (៣ដងx២៥) | ៧៥ | កក្កដា ២០១៩ | មិថុនា ២០២២ |

### ឃ.៣.៤. ការផ្សព្វផ្សាយផែនការគ្រប់គ្រងកន្លែងនេសាទសហគមន៍

ការផ្សព្វផ្សាយផែនការគ្រប់គ្រងកន្លែងនេសាទសហគមន៍ ត្រូវបានរៀបចំខាងក្រោម៖

| សកម្មភាព | ការប៉ាន់ស្មានថវិកា (ដុល្លារ) | ថ្ងៃខែឆ្នាំចាប់ផ្តើម | ថ្ងៃខែឆ្នាំបញ្ចប់ | អ្នកទទួលខុសត្រូវ |
|---|---|---|---|---|
| ផ្សព្វផ្សាយផែនការគ្រប់គ្រងកន្លែងនេសាទសហគមន៍ទៅសមាជិកសហគមន៍តាមរយៈបុណ្យទាន មហាសន្និបាតប្រចាំឆ្នាំ | ១៥០ (៣លើកx៥០) | កក្កដា ២០១៩ | មិថុនា ២០២២ | គណៈកម្មាការសហគមន៍នេសាទ |
| បញ្ចូលផែនការគ្រប់គ្រងកន្លែងនេសាទសហគមន៍ ទៅក្នុងកម្មវិធីវិនិយោគឃុំ | ៣០ (៣លើកx១០) | | | គណៈកម្មាការសហគមន៍នេសាទ |

### ឃ.៣.៥. ផែនការថវិកាទ្រទ្រង់សម្រាប់អភិវឌ្ឍន៍សហគមន៍

ផែនការថវិកាទ្រទ្រង់សម្រាប់អភិវឌ្ឍន៍សហគមន៍ ត្រូវបានរៀបចំខាងក្រោម ៖

| ប្រភេទប្រាក់ចំណូល | សកម្មភាព | ថ្ងៃខែឆ្នាំចាប់ផ្តើម | ថ្ងៃខែឆ្នាំបញ្ចប់ | ចំណូលសរុប (ដុល្លារ) | ផ្សេងៗ |
|---|---|---|---|---|---|
| ភាគទានពីសមាជិកសហគមន៍ | ចុះប្រមូលប្រាក់សមាជិកភាព | កក្កដា ២០១៩ | មិថុនា ២០២២ | ៣៦,២៥ | ១.០០០ រៀល/នាក់ ១៤៥នាក់) |
| ភាគទានប្រចាំឆ្នាំ | ចុះប្រមូលប្រាក់ភាគទានប្រចាំឆ្នាំ | | | ៥៤៣,៧៥ | ៥.០០០រៀល/នាក់ ក្នុងមួយឆ្នាំ(១៤៥នាក់) |
| ប្រាក់ចំណូលពីប្រភពផ្សេងៗ (អំណោយពីរាជរដ្ឋាភិបាល អំណោយពីសប្បុរសជន ជំនួយពីអង្គការជាតិ និងអង្គការដៃគូ) | • ទំនាក់ទំនងជាមួយស្ថាប័នជលផល<br>•សរសេរគម្រោងស្នើសុំពីអង្គការដៃគូ | | | ៩០.៩៣០ | សរសេរគម្រោងចំណាយថវិកា៥០០ដុល្លារ |
| | | | សរុប | ៩១.៥១០ | |

ង. ការតាមដាន ត្រួតពិនិត្យ និងវាយតម្លៃ

ការតាមដាន ត្រួតពិនិត្យ និងវាយតម្លៃ ត្រូវបានរៀបចំខាងក្រោម៖

| សកម្មភាព | ថ្ងៃខែឆ្នាំចាប់ផ្តើម | ថ្ងៃខែឆ្នាំបញ្ចប់ | អ្នកទទួលខុសត្រូវ | ផ្សេងៗ |
|---|---|---|---|---|
| ប្រជុំផ្ទៃក្នុង ប្រចាំត្រីមាសរបស់គណៈកម្មការសហគមន៍នេសាទ | កក្កដា ២០១៩ | មិថុនា ២០២២ | គណៈកម្មការសហគមន៍នេសាទ | ១២០ (១២ដងx១០) |
| រៀបចំមហាសន្និបាតសហគមន៍ប្រចាំឆ្នាំ ដោយមានការចូលរួមពី ស្ត្រី ជនជាតិដើមភាគតិច និងជនជាតិភាគតិច | កក្កដា ២០១៩ | មិថុនា ២០២២ | គណៈកម្មការសហគមន៍នេសាទ | ៦០០ (៣ដងx២០០) |

ច. យុទ្ធសាស្ត្រ

ដើម្បីអនុវត្តផែនការឱ្យទទួលបានជោគជ័យ យុទ្ធសាស្ត្រមួយចំនួនត្រូវបានរៀបចំដូចខាងក្រោម៖

- បង្កើតគណៈកម្មការសម្រាប់អនុវត្តតាមដានត្រួតពិនិត្យ និងវាយតម្លៃការអនុវត្តផែនការរួមមានសមាជិកគណៈកម្មការសហគមន៍នេសាទ ចាស់ទុំ សមាជិកសហគមន៍នេសាទ ដែលមានបទពិសោធន៍ និងចំណេះដឹងល្អ ជាពិសេសអំពីបញ្ហានេសាទ
- ស្នើសុំជំនួយបច្ចេកទេសពីរដ្ឋបាលជលផលមានសមត្ថកិច្ច ដើម្បីជួយផ្តល់យោបល់លើផែនការណា ដែលទាក់ទងនឹងបច្ចេកទេសជលផលដូចជាការធ្វើផែនការកន្លែងអភិរក្សត្រីមេពូជ ការរៀបចំកន្លែងអភិរក្សព្រៃលិចទឹក កន្លែងអភិរក្សជីវៈចម្រុះ ការស្តារព្រែក ការកំណត់ឧបករណ៍នេសាទ ការចិញ្ចឹមត្រី និងការរកថវិកាទ្រទ្រង់ជាដើម
- រៀបចំយុទ្ធសាស្ត្រទំនាក់ទំនងជាមួយស្ថាប័នជំនាញ អង្គការដៃគូ គម្រោង និងម្ចាស់ជំនួយ ដើម្បីទទួលបានការឧបត្ថម្ភគាំទ្រ និងថវិកាសម្រាប់ដំណើរការអនុវត្តផែនការ
- រៀបចំកម្មវិធីអនុវត្តផែនការតាមដំណាក់កាលនីមួយៗឱ្យបានជាក់លាក់
- ទាក់ទងជាមួយរដ្ឋបាលជលផល ដើម្បីសុំការគាំទ្រថវិកានិងជួយរកដៃគូសម្រាប់ទ្រទ្រង់ផែនការគ្រប់គ្រងសហគមន៍នេសាទ
- ផ្សព្វផ្សាយផែនការគ្រប់គ្រងកន្លែងនេសាទសហគមន៍ ដល់សមាជិកសហគមន៍នេសាទ និងអ្នកពាក់ព័ន្ធសំខាន់ៗ ដើម្បីជំរុញការចូលរួម និងគាំទ្រដល់ការអនុវត្តផែនការគ្រប់គ្រងនេះ
- កៀរគរការចូលរួមចំណែករបស់សមាជិកសហគមន៍នេសាទ
- រៀបចំវិធានការចំពោះអ្នកនេសាទមកពីក្រៅសហគមន៍
- ពង្រឹងសមត្ថភាពបច្ចេកទេស និងគ្រប់គ្រងរបស់គណៈកម្មការសហគមន៍នេសាទ
- ចងក្រងក្រុមអ្នកនេសាទទៅតាមប្រភេទឧបករណ៍នេសាទដើម្បីចូលរួមអនុវត្តផែនការ
- បញ្ចូលផែនការគ្រប់គ្រងកន្លែងនេសាទសហគមន៍ទៅក្នុងផែនការអភិវឌ្ឍន៍ និងកម្មវិធីវិនិយោគឃុំ

- ជ្រើសរើសស្ត្រីមេគ្រួសារ ជាសមាជិកចំនួនយ៉ាងតិច៧% ចូលរួមក្នុងសកម្មភាពទ្រទ្រង់ជីវភាពរស់នៅ
- អញ្ជើញស្ត្រីជាសមាជិកសហគមន៍នេសាទចូលរួមយ៉ាងតិច៤០% ក្នុងការបណ្តុះបណ្តាល សិក្ខាសាលា និងសកម្មភាព ទ្រទ្រង់ជីវភាពរស់នៅ និងវារីវប្បកម្ម
- កម្មករគ្មានជំនាញជាស្ត្រីជាសមាជិកសហគមន៍នេសាទ៤០%ចូលរួមសកម្មភាពហេដ្ឋារចនាសម្ព័ន្ធខ្នាតតូច
- អញ្ជើញស្ត្រីមេគ្រួសារ ស្ត្រីជនជាតិដើមភាគតិច និងជនជាតិភាគតិចជាសមាជិកសហគមន៍នេសាទ ចូលរួមប្រជុំ និងចូលរួមសកម្មភាពនានា និងចូលជាគណៈកម្មការរបស់សហគមន៍នេសាទ
- ជ្រើសរើសស្ត្រីជាសមាជិកសហគមន៍នេសាទ ៥០% ចូលរួមក្នុងសកម្មភាពគាំទ្រជីវភាព
- ផ្តល់ឱកាសស្ត្រី៥០%ជាសមាជិកសហគមន៍នេសាទចូលរួមក្នុងសកម្មភាពគាំទ្រជីវភាព និងទទួលផលប្រយោជន៍ពីគម្រោងក្នុងនោះស្ត្រីជាមេគ្រួសារ៧%
- លើកទឹកចិត្តស្ត្រីជាគណៈកម្មាការចូលរួមក្នុងការសម្រេចចិត្តនានា
- លើកទឹកចិត្តស្ត្រីជាគណៈកម្មាការមិនបោះបង់ចោលការងារ
- រៀបចំការប្រជុំឱ្យសមស្របនឹងពេលវេលារបស់ស្ត្រី ដែលមានលទ្ធភាពចូលរួម
- ជំរុញឱ្យមានស្ត្រីយ៉ាងតិច២៥% ជាសមាជិកគណកម្មាការសហគមន៍នេសាទ។

## តារាងសង្ខេបផែនការគ្រប់គ្រងតំបន់នេសាទសហគមន៍អន្លង់វាលព្រលូងលួងចិត្តរយៈពេល ៣ ឆ្នាំ (២០១៩-២០២២)

| ប្រភេទផែនការ | សកម្មភាព | លទ្ធផលរំពឹងទុក | ការប៉ាន់ស្មានថវិកា(ដុល្លារ) | ប្រភពថវិកា | ពេលចាប់ផ្តើម | ពេលបញ្ចប់ | ផ្សេងៗ |
|---|---|---|---|---|---|---|---|
| យ.១. ធនធានជលផល និងអេកូឡូស៊ី | | | | | | | |
| យ.១.១. ផែនការប្រើប្រាស់ឧបករណ៍នេសាទ | ផ្សព្វផ្សាយពីប្រភេទឧបករណ៍នេសាទដែលអនុញ្ញាត ទំហំ ពេលវេលា និងទីកន្លែងនេសាទនិងប្រភេទឧបករណ៍នេសាទហាមឃាត់ | ផែនការប្រើប្រាស់ឧបករណ៍នេសាទត្រូវបានផ្សព្វផ្សាយ ២ដង ក្នុង០១ឆ្នាំ (រដូវបិទ និងបើកនេសាទ) | ១៥០ | រដ្ឋបាលជលផល អង្គការដៃគូ សហគមន៍នេសាទ | កក្កដា ២០១៩ | មិថុនា ២០២២ | |
| យ.១.២. ផែនការកំណត់ និងរៀបចំកន្លែងអភិរក្សសហគមន៍ | ដាក់ស្លាកសញ្ញាតាមអន្លង់អភិរក្ស | ស្លាកសញ្ញាតាមអន្លង់អភិរក្សចំនួន១២ ត្រូវបានដាក់ | ២.៤០០ | រដ្ឋបាលជលផល អង្គការដៃគូ | កក្កដា ២០១៩ | ធ្នូ ២០១៩ | |
| | តម្លើងផ្ទាំងផ្សព្វផ្សាយអំពីច្បាប់ជលផល និងការអភិរក្ស | ផ្ទាំងផ្សព្វផ្សាយអំពីច្បាប់ជលផល និងការអភិរក្សចំនួន ២ ផ្ទាំងត្រូវបានតំលើង | ៤០០ | | | | |
| | លែងកូនត្រីពូជ | កូនត្រីពូជរួមមានៈ ត្រីគ្រីខ្លា ត្រីឆ្ពិន ត្រីប្រា ត្រីខ្យា ត្រីឆ្លោក ត្រីគល់រាំង ត្រីគ្រសក់ ត្រូវបានលែងចូលក្នុងអន្លង់ | ១.៥០០ | | កក្កដា ២០១៩ | មិថុនា ២០២២ | (៥០០/១ឆ្នាំ) |
| យ.១.៣. ផែនការបោះបង្គោលព្រំប្រទល់ និងផ្ទាំងប៉ាណូផែនទីកន្លែងនេសាទសហគមន៍ | រៀបចំ និងលើកផ្ទាំងប៉ាណូផែនទីកន្លែងនេសាទសហគមន៍ | ផ្ទាំងប៉ាណូផែនទីកន្លែងនេសាទសហគមន៍២ផ្ទាំងត្រូវបានតម្លើង | ៣០០ | រដ្ឋបាលជលផល អង្គការដៃគូ | តុលា ២០១៩ | ធ្នូ ២០១៩ | |
| យ.១.៤. ផែនការគ្រប់គ្រងព្រៃលិចទឹក | ដាំព្រៃលិចទឹកតាមច្រាំងទន្លេ និងមាត់អូរ ចាប់ពីដើមភូមិដល់ចុងភូមិ | ព្រៃលិចទឹកដែលត្រូវការពារព្រមទាំងដាំឡើងវិញរួមមានៈ ត្រែង រៃ គ្រស់ រាំង ទន្លា | ៣០០ | រដ្ឋបាលជលផល អង្គការដៃគូ | កក្កដា ២០១៩ | មិថុនា ២០២២ | (១០០/១ឆ្នាំ) |



th

| ប្រភេទផែនការ | សកម្មភាព | លទ្ធផលរំពឹងទុក | ការប៉ាន់ស្មានថវិកា(ដុល្លារ) | ប្រភពថវិកា | ពេលចាប់ផ្តើម | ពេលបញ្ចប់ | ផ្សេងៗ |
|---|---|---|---|---|---|---|---|
| ឃ.២. គាំទ្រជីវភាពប្រជាពលរដ្ឋ | | | | | | | |
| ឃ.២.១. ផែនការមុខរបរបង្កើនប្រាក់ចំណូល | ចិញ្ចឹមមាន់តាមបច្ចេកទេសជាលក្ខណៈគ្រួសារ | ៣០ គ្រួសារ | ១.៥០០ | រដ្ឋបាលជលផល អង្គការដៃគូ | កក្កដា ២០១៩ | មិថុនា ២០២២ | ២០.០០០រៀល/ក្បាល និង ១០ក្បាល/គ្រួសារ |
| | ចិញ្ចឹមទាតាមបច្ចេកទេសជាលក្ខណៈគ្រួសារ | ២០ គ្រួសារ | ១.០០០ | | | | ២០.០០០រៀល/១ក្បាល (១០ក្បាល/គ្រួសារ) |
| | ចិញ្ចឹមគោតាមបច្ចេកទេសជាលក្ខណៈគ្រួសារ | ៥០ គ្រួសារ | ១៥.០០០ | | | | ៣០០ដុល្លារ/ក្បាល |
| | ចិញ្ចឹមជ្រូកតាម បច្ចេកទេសជាលក្ខណៈគ្រួសារ | ៥ គ្រួសារ | ៥០០ | | | | ៥០ដុល្លារ/១ក្បាល និង ២ក្បាល/១គ្រួសារ |
| | រៀបចំសួនបន្លែតាមលក្ខណៈគ្រួសារ | ១៥ គ្រួសារ | ៧៥០ | | | | |
| | បណ្តុះផ្សិត | ៥ គ្រួសារ | ២៥០ | | | | |
| | ធ្វើមេផ្សិត | ១ គ្រួសារ | ៣០០ | | | | |
| ឃ.២.២. ផែនការអភិវឌ្ឍន៍វារីវប្បកម្ម | ចិញ្ចឹមត្រីអណ្តែងក្នុងអាងតាមបច្ចេកទេសជាលក្ខណៈគ្រួសារ | សមាជិកសហគមន៍៥គ្រួសារមានជំនាញ ចិញ្ចឹមត្រី និងអាចរកប្រាក់ចំណូល ធ្វើឱ្យជីវភាពប្រសើរឡើង | ២.៥០០ | រដ្ឋបាលជលផល អង្គការដៃគូ | កក្កដា ២០១៩ | មិថុនា ២០២២ | |
| ឃ.២.៣. ផែនការរៀបចំ និងពង្រឹងក្រុមសន្សំប្រាក់ | បង្កើតក្រុមសន្សំប្រាក់ចំនួន ៣ ក្រុមបន្ថែម | ក្រុមសន្សំប្រាក់ចំនួន ៣ ក្រុម ត្រូវបានបង្កើតឡើង | ៩០០ | រដ្ឋបាលជលផល អង្គការដៃគូ | កក្កដា ២០១៩ | មិថុនា ២០២២ | |
| ឃ.២.៤. ផែនការរៀបចំសហគមន៍ និងហេដ្ឋារចនាសម្ព័ន្ធ | ជួសជុលផ្លូវលំក្នុងភូមិ | ផ្លូវលំ១ខ្សែប្រវែង ២.០០០ម ត្រូវបានជួសជុល និងប្រើជាប្រយោជន៍រួមរបស់សហគមន៍ | ២០.០០០ | រដ្ឋបាលជលផល អង្គការដៃគូ | កក្កដា ២០១៩ | មិថុនា ២០២២ | |

| ប្រភេទផែនការ | សកម្មភាព | លទ្ធផលរំពឹងទុក | ការប៉ាន់ស្មានថវិកា(ដុល្លារ) | ប្រភពថវិកា | ពេលចាប់ផ្តើម | ពេលបញ្ចប់ | ផ្សេងៗ |
|---|---|---|---|---|---|---|---|
| | ជួសជុលស្ពានឈើក្នុងភូមិ | ស្ពានឈើចំនួន ២ ត្រូវបានជួសជុល និងប្រើជាប្រយោជន៍រួមរបស់សហគមន៍នេសាទ | ២០.០០០ | រដ្ឋបាលជលផល អង្គការដៃគូ | កក្កដា ២០១៩ | មិថុនា ២០២២ | |
| | ដាក់លូកាត់ផ្លូវ | លូកាត់ទទឹងផ្លូវចំនួន ២ កន្លែងត្រូវបានដាក់ឡើងវិញ | ៣.០០០ | រដ្ឋបាលជលផល អង្គការដៃគូ | | | |
| ឃ.៣. ការងារគ្រប់គ្រង | | | | | | | |
| ឃ.៣.១. ផែនការសកម្មភាពចុះល្បាតទប់ស្កាត់បទល្មើស | សហគមន៍ចុះល្បាតដោយខ្លួនឯង | ៥ដង/ខែ | ៤.៥០០ | រដ្ឋបាលជលផល អង្គការដៃគូ | កក្កដា ២០១៩ | មិថុនា ២០២២ | |
| | ចុះល្បាតដោយសហការជាមួយអាជ្ញាធរមូលដ្ឋានដើម្បីទប់ស្កាត់បទល្មើសមកពីក្រៅ | ២ដង/ខែ | ១.៨០០ | | | | |
| | ផ្តល់សម្ភារល្បាត | ១ឈុត | ១.០០០ | | កក្កដា ២០១៩ | កញ្ញា ២០១៩ | |
| | ទិញទូកស្ពាច់និងម៉ាស៊ីន | ២គ្រឿង (១តូច ១ធំ) | ៣.០០០ | | | | |
| | ទិញប្រេងសម្រាប់ល្បាត | ១០០លីត្រ/១ខែ | ៣.៦០០ | | កក្កដា ២០១៩ | មិថុនា ២០២២ | |
| | ជួសជុលនិងថែទាំទូក និងម៉ាស៊ីន | ២ដង/ឆ្នាំ | ៦០០ | | | | |
| | សាងសង់ទីស្នាក់ការសហគមន៍ | ស្នាក់ការចំនួន១ត្រូវបានសាងសង់ | ៣.០០០ | | កក្កដា ២០១៩ | កញ្ញា ២០១៩ | |
| ឃ.៣.២. ផែនការពង្រឹងគណៈកម្មការសហគមន៍នេសាទ | ប្រជុំប្រចាំខែរបស់គណៈកម្មការសហគមន៍នេសាទ | ១ដង/១ខែ | ៣៦០ | រដ្ឋបាលជលផល អង្គការដៃគូ សហគមន៍នេសាទ | កក្កដា ២០១៩ | មិថុនា ២០២២ | |
| | ចូលរួមប្រជុំប្រចាំខែជាមួយក្រុមប្រឹក្សាឃុំ | ១ដង/១ខែ | ៣៦០ | | | | |
| | បណ្តុះបណ្តាលអំពីរបៀបធ្វើកំណត់ហេតុ សរសេរលិខិតរដ្ឋបាល របាយការណ៍ និងរៀបចំទុកដាក់ | ១លើក/១ឆ្នាំ | ៦០ | | | | |

| ប្រភេទផែនការ | សកម្មភាព | លទ្ធផលរំពឹងទុក | ការប៉ាន់ស្មានថវិកា(ដុល្លារ) | ប្រភពថវិកា | ពេលចាប់ផ្តើម | ពេលបញ្ចប់ | ផ្សេងៗ |
|---|---|---|---|---|---|---|---|
| | ឯកសារ | | | | | | |
| | បណ្តុះបណ្តាលអំពីការដោះស្រាយទំនាស់ | ១លើក/១ឆ្នាំ | ៦០ | | កក្កដា ២០១៩ | មិថុនា ២០២២ | |
| | បណ្តុះបណ្តាលអំពីភាពជាអ្នកដឹកនាំ | ១លើក/១ឆ្នាំ | ៦០ | | | | |
| | បណ្តុះបណ្តាលអំពីការរៀបចំផែនការសកម្មភាពការងារ | ១លើក/១ឆ្នាំ | ៦០ | | | | |
| | បណ្តុះបណ្តាលអំពីការកត់ត្រាចំណាយចំណូល | ១លើក/១ឆ្នាំ | ៦០ | | | | |
| | បណ្តុះបណ្តាលអំពីការសរសេរសំណើថវិកា | ១លើក/១ឆ្នាំ | ៦០ | | | | |
| ឃ.៣.៣. ផែនការបង្កើនការយល់ដឹងដល់សមាជិកសហគមន៍នេសាទ | ផ្សព្វផ្សាយលក្ខន្តិកៈ និងបទបញ្ជាផ្ទៃក្នុងសហគមន៍នេសាទ | ២ដង/ឆ្នាំ | ១៥០ | រដ្ឋបាលជលផល អង្គការដៃគូ សហគមន៍នេសាទ | កក្កដា ២០១៩ | មិថុនា ២០២២ | ១ឆ្នាំ ២ដង |
| | ផ្សព្វផ្សាយកិច្ចព្រមព្រៀងសហគមន៍ | ១ដង/ឆ្នាំ | ៧៥ | | | | |
| | ផ្សព្វផ្សាយដែននេសាទនិងកន្លែងអភិរក្សរបស់សហគមន៍នេសាទ | ១ដង/ឆ្នាំ | ៧៥ | | | | |
| | ផ្សព្វផ្សាយពីការប្រមូលប្រាក់បដិភាគ | ១ដង/ឆ្នាំ | ៣០ | | | | |
| | ផ្សព្វផ្សាយច្បាប់ជលផល និងលិខិតបទដ្ឋានគតិយុទ្ធពាក់ព័ន្ធ | ១ដង/ឆ្នាំ | ៧៥ | | | | |
| | យុទ្ធនាការផ្សព្វផ្សាយការយល់ដឹងអំពីសារប្រយោជន៍ធនធានជលផល | ១ដង/ឆ្នាំ | ៣០០ | | | | |
| | ប្រជុំផ្សព្វផ្សាយតួនាទីរបស់បុរសស្ត្រីក្នុងសហគមន៍នេសាទ និងការងារផ្ទះ សមភាពនិងសមធម៌យេនឌ័រ | ១ដង/ឆ្នាំ | ៧៥ | | | | |



th

| ប្រភេទផែនការ | សកម្មភាព | លទ្ធផលរំពឹងទុក | ការប៉ាន់ស្មានថវិកា(ដុល្លារ) | ប្រភពថវិកា | ពេលចាប់ផ្តើម | ពេលបញ្ចប់ | ផ្សេងៗ |
|---|---|---|---|---|---|---|---|
| ឃ.៣.៤. ការផ្សព្វផ្សាយផែនការគ្រប់គ្រងកន្លែងនេសាទសហគមន៍ | ផ្សព្វផ្សាយផែនការគ្រប់គ្រងកន្លែងនេសាទសហគមន៍ទៅសមាជិកសហគមន៍តាមរយៈបុណ្យទានមហាសន្និបាតប្រចាំឆ្នាំ | ១ដង/ឆ្នាំ | ១៥០ | រដ្ឋបាលជលផល អង្គការដៃគូ សហគមន៍នេសាទ | កក្កដា ២០១៩ | មិថុនា ២០២២ | |
| | បញ្ចូលផែនការគ្រប់គ្រងកន្លែងនេសាទសហគមន៍ ទៅក្នុងកម្មវិធីវិនិយោគឃុំ | ១ដង/ឆ្នាំ | ៣០ | គណៈកម្មការ | | | |
| ឃ.៣.៥. ផែនការថវិកាទ្រទ្រង់សម្រាប់អភិវឌ្ឍន៍សហគមន៍ | ភាគទានពីសមាជិកសហគមន៍នេសាទ | សមាជិកសហគមន៍ បានបង់ភាគទានសមាជិកភាព | ៣៦.២៥ | សហគមន៍នេសាទ | កក្កដា ២០១៩ | មិថុនា ២០២២ | |
| | ភាគទានប្រចាំឆ្នាំពីសមាជិកសហគមន៍នេសាទ | ១ឆ្នាំម្តង | ៥៤៣,៧៥ | | | | |
| | ប្រាក់ចំណូលពីប្រភពផ្សេងៗ (អំណោយពីរាជរដ្ឋាភិបាល អំណោយពីសប្បុរសជន ជំនួយពីអង្គការជាតិ និងអង្គការដៃគូ) | សហគមន៍នេសាទទទួលបានកញ្ចប់ថវិកាពីប្រភពផ្សេងៗ | ៩០.៩៣០ | រដ្ឋបាលជលផល អង្គការដៃគូ | | | |
| ង. ការតាមដាន ត្រួតពិនិត្យ និងវាយតម្លៃ | ប្រជុំផ្ទៃក្នុង ប្រចាំត្រីមាសរបស់គណៈកម្មការសហគមន៍នេសាទ | ៤ដង/ឆ្នាំ | ១២០ | រដ្ឋបាលជលផល អង្គការដៃគូ | កក្កដា ២០១៩ | មិថុនា ២០២២ | |
| | រៀបចំមហាសន្និបាតសហគមន៍ប្រចាំឆ្នាំ ដោយមានការចូលរួមពីស្ត្រី ជនជាតិដើមភាគតិច និងជនជាតិភាគតិច | ១ដង/ឆ្នាំ | ៦០០ | រដ្ឋបាលជលផល អង្គការដៃគូ | | | |



th

## តារាងកម្មវិធីការងារប្រចាំឆ្នាំ ( កក្កដា ២០១៩ - មិថុនា ២០២២ )

| សកម្មភាព | ពេលវេលា | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| | ២០១៩ | | | | | | ២០២០ | | | | | | | | | | | | ២០២១ | | | | | | | | | | | | ២០២២ | | | | | |
| | ៧ | ៨ | ៩ | ១០ | ១១ | ១២ | ១ | ២ | ៣ | ៤ | ៥ | ៦ | ៧ | ៨ | ៩ | ១០ | ១១ | ១២ | ១ | ២ | ៣ | ៤ | ៥ | ៦ | ៧ | ៨ | ៩ | ១០ | ១១ | ១២ | ១ | ២ | ៣ | ៤ | ៥ | ៦ |
| ឃ.១. ធនធានជលផល និងអេកូឡូស៊ី | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | |
| ឃ.១.១. ផែនការប្រើប្រាស់ឧបករណ៍នេសាទ | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | |
| ផ្សព្វផ្សាយពីប្រភេទឧបករណ៍នេសាទដែលអនុញ្ញាត ទំហំ ពេលវេលា ទីកន្លែងនេសាទ និងប្រភេទឧបករណ៍នេសាទហាមឃាត់ | | | | X | | | | | | | X | | | | | X | | | | | | | X | | | | | X | | | | | | | X | |
| ឃ.១.២. ផែនការកំណត់ និងរៀបចំកន្លែងអភិរក្សសហគមន៍នេសាទ | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | |
| ដាក់ស្លាកសញ្ញាតាមអន្លង់អភិរក្ស | X | X | X | X | X | X | | | | | | | | | | | | | | | | | | | | | | | | | | | | | | |
| តម្លើងផ្ទាំងផ្សព្វផ្សាយអំពីច្បាប់ជលផល និងការអភិរក្ស | X | X | X | X | X | X | | | | | | | | | | | | | | | | | | | | | | | | | | | | | | |
| លែងកូនត្រីពូជ | X | | | | | | | | | | | | X | | | | | | | | | | | | X | | | | | | | | | | | |
| ឃ.១.៣. ផែនការបោះបង្គោលព្រំប្រទល់ និងផ្ទាំងប៉ាណូផែនទីកន្លែងនេសាទសហគមន៍ | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | |
| រៀបចំ និងលើកផ្ទាំងប៉ាណូផែនទីកន្លែងនេសាទសហគមន៍ | | | | X | X | X | | | | | | | | | | | | | | | | | | | | | | | | | | | | | | |
| ឃ.១.៤. ផែនការគ្រប់គ្រងព្រៃលិចទឹក | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | |
| ដាំព្រៃលិចទឹកតាមច្រាំងទន្លេ មាត់អូរ និងមាត់អូរចាប់ពីដើមភូមិដល់ចុងភូមិ | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X |
| ឃ.២. គាំទ្រជីវភាពប្រជាពលរដ្ឋ | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | |

| សកម្មភាព | ពេលវេលា | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| | ២០១៩ | | | | | | ២០២០ | | | | | | | | | | | | ២០២១ | | | | | | | | | | | | ២០២២ | | | | | |
| | ៧ | ៨ | ៩ | ១០ | ១១ | ១២ | ១ | ២ | ៣ | ៤ | ៥ | ៦ | ៧ | ៨ | ៩ | ១០ | ១១ | ១២ | ១ | ២ | ៣ | ៤ | ៥ | ៦ | ៧ | ៨ | ៩ | ១០ | ១១ | ១២ | ១ | ២ | ៣ | ៤ | ៥ | ៦ |
| **ឃ.២.១. ផែនការមុខរបរបង្កើនប្រាក់ចំណូល** | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | |
| ចិញ្ចឹមមាន់តាមបច្ចេកទេសជាលក្ខណៈគ្រួសារ | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X |
| ចិញ្ចឹមទាតាមបច្ចេកទេសជាលក្ខណៈគ្រួសារ | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X |
| ចិញ្ចឹមគោតាមបច្ចេកទេសជាលក្ខណៈគ្រួសារ | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X |
| ចិញ្ចឹមជ្រូកតាមបច្ចេកទេសជាលក្ខណៈគ្រួសារ | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X |
| រៀបចំសួនបន្លែតាមលក្ខណៈគ្រួសារ | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X |
| បណ្តុះ ផ្សិត | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X |
| ធ្វើមេផ្សិត | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X |
| **ឃ.២.២. ផែនការអភិវឌ្ឍន៍វារីវប្បកម្ម** | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | |
| ចិញ្ចឹមត្រីអណ្តែងក្នុងអាងតាមបច្ចេកទេសជាលក្ខណៈគ្រួសារ | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X |
| **ឃ.២.៣. ផែនការរៀបចំ និងពង្រឹងក្រុមសន្សំប្រាក់** | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | |
| បង្កើតក្រុមសន្សំប្រាក់បន្ថែម | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X |
| **ឃ.២.៤. ផែនការសេវាសហគមន៍ និងហេដ្ឋារចនាសម្ព័ន្ធ** | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | |
| ជួសជុលផ្លូវលំក្នុងភូមិ | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X |
| ជួសជុលស្ពានឈើក្នុងភូមិ | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X |

| សកម្មភាព | ពេលវេលា | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| | ២០១៩ | | | | | | ២០២០ | | | | | | | | | | | | ២០២១ | | | | | | | | | | | | ២០២២ | | | | | |
| | ៧ | ៨ | ៩ | ១០ | ១១ | ១២ | ១ | ២ | ៣ | ៤ | ៥ | ៦ | ៧ | ៨ | ៩ | ១០ | ១១ | ១២ | ១ | ២ | ៣ | ៤ | ៥ | ៦ | ៧ | ៨ | ៩ | ១០ | ១១ | ១២ | ១ | ២ | ៣ | ៤ | ៥ | ៦ |
| ដាក់លូកាត់ផ្លូវ | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X |
| **ឃ.៣. ការគ្រប់គ្រង** | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | |
| **ឃ.៣.១. ផែនការសកម្មភាពចុះល្បាតទប់ស្កាត់បទល្មើស** | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | |
| សហគមន៍ចុះល្បាតដោយខ្លួនឯង | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X |
| ចុះល្បាតដោយសហការជាមួយអាជ្ញាធរមូលដ្ឋានដើម្បីទប់ស្កាត់បទល្មើសមកពីក្រៅ | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X |
| ផ្តល់សម្ភារល្បាត | X | X | X | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | |
| ទិញទូកស្ពាច់ និងម៉ាស៊ីន | X | X | X | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | |
| ទិញប្រេងសម្រាប់ល្បាត | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X |
| ជួសជុលនិងថែទាំទូក ម៉ាស៊ីន | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X |
| សាងសង់ទីស្នាក់ការសហគមន៍ | X | X | X | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | |
| **ឃ.៣.២. ផែនការពង្រឹងគណៈកម្មការសហគមន៍នេសាទ** | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | |
| ប្រជុំប្រចាំខែរបស់គណៈកម្មការសហគមន៍នេសាទ | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X |
| ចូលរួមប្រជុំប្រចាំខែជាមួយក្រុមប្រឹក្សាឃុំ | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X |
| បណ្តុះបណ្តាលអំពីរបៀបធ្វើកំណត់ហេតុ សរសេរលិខិតរដ្ឋបាលរបាយការណ៍ និងរៀបចំទុកឯកសារ | | | | | | | | | | | | X | | | | | | | | | | | | X | | | | | | | | | | | | X |
| បណ្តុះបណ្តាលអំពីការដោះ | | | X | | | | | | | | | | | | X | | | | | | | | | | | | X | | | | | | | | | |

| សកម្មភាព | ពេលវេលា | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| | ២០១៩ | | | | | | ២០២០ | | | | | | | | | | | | ២០២១ | | | | | | | | | | | | ២០២២ | | | | | |
| | ៧ | ៨ | ៩ | ១០ | ១១ | ១២ | ១ | ២ | ៣ | ៤ | ៥ | ៦ | ៧ | ៨ | ៩ | ១០ | ១១ | ១២ | ១ | ២ | ៣ | ៤ | ៥ | ៦ | ៧ | ៨ | ៩ | ១០ | ១១ | ១២ | ១ | ២ | ៣ | ៤ | ៥ | ៦ |
| ស្រាយទំនាស់ | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | |
| បណ្តុះបណ្តាលអំពីភាពជាអ្នកដឹកនាំ | | | | | X | | | | | | | | | | | X | | | | | | | | | | | | X | | | | | | | | |
| បណ្តុះបណ្តាលអំពីការរៀបចំផែនការសកម្មភាពការងារ | | | | | | X | | | | | | | | | | | X | | | | | | | | | | | | X | | | | | | | |
| បណ្តុះបណ្តាលអំពីការកត់ត្រាចំណាយចំណូល | | | | | | | X | | | | | | | | | | | X | | | | | | | | | | | | X | | | | | | |
| បណ្តុះបណ្តាលអំពីការសរសេរសំណើថវិកា | | | | | | | | X | | | | | | | | | | | X | | | | | | | | | | | | X | | | | | |
| យ.៣.៣. ផែនការបង្កើនការយល់ដឹងដល់សមាជិកសហគមន៍នេសាទ | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | |
| ផ្សព្វផ្សាយលក្ខន្តិកៈ និងបទបញ្ជាផ្ទៃ ក្នុងសហគមន៍នេសាទ | | X | | | | | | | | | X | | | X | | | | | | | | | X | | | X | | | | | | | | | X | |
| ផ្សព្វផ្សាយកិច្ចព្រមព្រៀងសហគមន៍នេសាទ | | X | | | | | | | | | | | | X | | | | | | | | | | | | X | | | | | | | | | | |
| ផ្សព្វផ្សាយដែននេសាទនិងកន្លែងអភិរក្សរបស់សហគមន៍ | | X | | | | | | | | | | | | X | | | | | | | | | | | | X | | | | | | | | | | |
| ផ្សព្វផ្សាយពីការប្រមូលប្រាក់បដិភាគ | | | | | | | | X | | | | | | | | | | | | X | | | | | | | | | | | | X | | | | |
| ផ្សព្វផ្សាយច្បាប់ជលផល និងលិខិតបទដ្ឋានគតិយុទ្ធពាក់ព័ន្ធ | | | X | | | | | | | | | | | | X | | | | | | | | | | | | X | | | | | | | | | |
| យុទ្ធនាការផ្សព្វផ្សាយការយល់ | | X | | | | | | | | | | | | X | | | | | | | | | | | | X | | | | | | | | | | |



th

| សកម្មភាព | ពេលវេលា | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| | ២០១៩ | | | | | | ២០២០ | | | | | | | | | | | | ២០២១ | | | | | | | | | | | | ២០២២ | | | | | |
| | ៧ | ៨ | ៩ | ១០ | ១១ | ១២ | ១ | ២ | ៣ | ៤ | ៥ | ៦ | ៧ | ៨ | ៩ | ១០ | ១១ | ១២ | ១ | ២ | ៣ | ៤ | ៥ | ៦ | ៧ | ៨ | ៩ | ១០ | ១១ | ១២ | ១ | ២ | ៣ | ៤ | ៥ | ៦ |
| ដឹងសារប្រយោជន៍ធនធានជលផល | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | |
| ប្រជុំផ្សព្វផ្សាយអំពីតួនាទីរបស់បុរស ស្ត្រីក្នុងសហគមន៍នេសាទ និងការងារផ្ទះ សមភាពនិងសមធម៌យេនឌ័រ | | | | | X | | | | | | | | | | | X | | | | | | | | | | | | X | | | | | | | | |
| ឃ.៣.៤. ការផ្សព្វផ្សាយផែនការគ្រប់គ្រងកន្លែងនេសាទសហគមន៍ | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | |
| ផ្សព្វផ្សាយផែនការគ្រប់គ្រងកន្លែងនេសាទសហគមន៍ទៅសមាជិកសហគមន៍តាមរយៈបុណ្យទានមហាសន្និបាតប្រចាំឆ្នាំ | | | | | | X | | | | | | | | | | | | X | | | | | | | | | | | | X | | | | | | |
| បញ្ចូលផែនការគ្រប់គ្រងកន្លែងនេសាទសហគមន៍ ទៅក្នុងកម្មវិធីវិនិយោគឃុំ | X | X | | | | | | | | | | | X | X | | | | | | | | | | | X | X | | | | | | | | | | |
| ឃ.៣.៥. ផែនការថវិកាទ្រទ្រង់សម្រាប់អភិវឌ្ឍន៍សហគមន៍នេសាទ | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | |
| ភាគទានពីសមាជិកស.ន | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X |
| ភាគទានប្រចាំឆ្នាំ | | | | | | | | X | | | | | | | | | | | | X | | | | | | | | | | | | X | | | | |
| ភាគទានប្រចាំឆ្នាំពីជង្រុកស្រូវសហគមន៍នេសាទ | | | | | | | X | | | | | | | | | | | | X | | | | | | | | | | | | X | | | | | |
| ប្រាក់ចំណូលពីប្រភពផ្សេងៗ | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X |
| ង. ការតាមដាន ត្រួតពិនិត្យ និងវាយតម្លៃ | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | |

| សកម្មភាព | ពេលវេលា | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| | ២០១៩ | | | | | | ២០២០ | | | | | | | | | | | | ២០២១ | | | | | | | | | | | | ២០២២ | | | | | |
| | ៧ | ៨ | ៩ | ១០ | ១១ | ១២ | ១ | ២ | ៣ | ៤ | ៥ | ៦ | ៧ | ៨ | ៩ | ១០ | ១១ | ១២ | ១ | ២ | ៣ | ៤ | ៥ | ៦ | ៧ | ៨ | ៩ | ១០ | ១១ | ១២ | ១ | ២ | ៣ | ៤ | ៥ | ៦ |
| ប្រជុំផ្ទៃក្នុង ប្រចាំត្រីមាសរបស់គណៈកម្មការសហគមន៍នេសាទ | | | X | | | X | | | X | | | X | | | X | | | X | | | X | | | X | | | X | | | X | | | X | | | X |
| រៀបចំមហាសន្និបាតសហគមន៍ប្រចាំឆ្នាំ ដោយមានការចូលរួមពីស្ត្រី ជនជាតិដើមភាគតិច និងជនជាតិភាគតិច | | | | | | X | | | | | | | | | | | | X | | | | | | | | | | | | X | | | | | | |

សូមគោរពជូន
លោកមេឃុំកំពង់ចាម
"ដើម្បីជូនពិនិត្យ និងសម្រួល"
ថ្ងៃ[illegible] ខែ[illegible] ឆ្នាំកុរ ឯកស័ក ព.ស.២៥៦៣
ភូមិអំពិលទឹក ថ្ងៃទី២៤ ខែ តុលា ឆ្នាំ២០១៩
ប្រធានគណៈកម្មការសហគមន៍នេសាទ
អន្លង់វាលព្រលួងលួងចិត្ត

ប៉ុន វាសនា

លេខ ៍០៧២/១៩
បានឃើញ និងគោរពជូន
លោកនាយសង្កាត់រដ្ឋបាលជលផលសំបូរ
"ដើម្បីជូនពិនិត្យ និងសម្រួល"
ថ្ងៃ[illegible] ខែ[illegible] ឆ្នាំកុរ ឯកស័ក ព.ស.២៥៦៣
ឃុំកំពង់ចាម ថ្ងៃទី២៤ ខែ តុលា ឆ្នាំ២០១៩
មេឃុំកំពង់ចាម

រះមិត ណារិន

លេខ ១៨ ន.ក.ជ.ស.ប
បានឃើញ និងគោរពជូន
លោកនាយផ្នែករដ្ឋបាលជលផលកាំពី
"ដើម្បីជូនពិនិត្យ និងសម្រួល"
ថ្ងៃ[illegible] ខែ[illegible] ឆ្នាំកុរ ឯកស័ក ព.ស.២៥៦៣
សំបូរ ថ្ងៃទី ២៩ ខែ តុលា ឆ្នាំ២០១៩
នាយសង្កាត់រដ្ឋបាលជលផលសំបូរ

ស៊ុំ ចាណារ័ត្ន

លេខ : ០៥០ ក.រ.ក.ព

បានឃើញ និងគោរពជូន

លោកនាយខណ្ឌរដ្ឋបាលជលផលក្រចេះ

"ដើម្បីជូនពិនិត្យ និងសម្រួល"

ថ្ងៃ............ ខែ............ ឆ្នាំកុរ ឯកស័ក ព.ស.២៥៦៣

កាំពី ថ្ងៃទី ២៦ ខែ កក្កដា ឆ្នាំ២០១៩

ក.នាយផ្នែករដ្ឋបាលជលផលកាំពី

គុ សុវណ្ណារី

---

លេខ : ១២៣ ខ.ក្រចេះ

បានឃើញ និងគោរពជូន

លោកប្រធាន

មន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទខេត្តក្រចេះ

"ដើម្បីជូនពិនិត្យ និងសម្រួល"

ថ្ងៃ............ ខែ............ ឆ្នាំកុរ ឯកស័ក ព.ស.២៥៦៣

ក្រចេះ ថ្ងៃទី ២៦ ខែ កក្កដា ឆ្នាំ២០១៩

នាយខណ្ឌរដ្ឋបាលជលផលក្រចេះ

សៀន គិន

---

លេខ : ១៥៥ កសក.ក្រច

បានឃើញ និងគោរពជូន

ឯកឧត្តមប្រតិភូរាជរដ្ឋាភិបាលកម្ពុជា ទទួលបន្ទុកជា

ប្រធានរដ្ឋបាលជលផល

"ដើម្បីជូនពិនិត្យ និងសម្រេចដោយអនុគ្រោះ"

ថ្ងៃ............ ខែ............ ឆ្នាំកុរ ឯកស័ក ព.ស.២៥៦៣

ក្រចេះ ថ្ងៃទី ៣០ ខែ កក្កដា ឆ្នាំ២០១៩

ប្រធាន

មន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទខេត្តក្រចេះ

ទ្រី សុភក្ដិ

---

លេខ : ២២០៤......

បានឃើញ និងឯកភាព

ថ្ងៃ............ ខែ............ ឆ្នាំកុរ ឯកស័ក ព.ស.២៥៦៣

រាជធានីភ្នំពេញ ថ្ងៃទី៣១ ខែ កក្កដា ឆ្នាំ២០១៩

**ប្រតិភូរាជរដ្ឋាភិបាលកម្ពុជា ទទួលបន្ទុកជា**

**ប្រធានរដ្ឋបាលជលផល**

២៦ អេង ជាសាន